# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ១៧៣/០៧ គ.ជ.ប

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**ជំរាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ** : សំណើសុំជួយរំលឹកដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ ឱ្យយកចិត្តទុកដាក់ផ្សព្វផ្សាយព័ត៌មានបែបសមធម៌ និងយុត្តិធម៌ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២

**យោង** : - បទបញ្ជា និងនីតិវិធី គ.ជ.ប សម្រាប់ការបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី ២ ឧបសម្ព័ន្ធទី ៧ ស្តីពី គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
- លិខិតលេខ ០៦៦/០៧ គ.ជ.ប ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧

តាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា ដើម្បីរក្សាបរិយាកាសល្អ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោតឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ នេះ សូមឯកឧត្តមជួយអន្តរាគមន៍ និងរំលឹកដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ ឱ្យយកចិត្តទុកដាក់គោរពតាមគោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលបានចែងថា " ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ រដ្ឋ និងឯកជន ត្រូវធ្វើការបែងចែកឱ្យបានច្បាស់ក្នុងការផ្សព្វផ្សាយព័ត៌មាន អំពីសកម្មភាពផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោត ដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ " ។

ជាពិសេស គ.ជ.ប ស្នើសុំឯកឧត្តមជួយអន្តរាគមន៍ ដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ឱ្យផ្សព្វផ្សាយព័ត៌មានដែលមានលក្ខណៈ ជាព័ត៌មានសមធម៌ និងយុត្តិធម៌ សម្រាប់គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ នេះ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រី ជួយបន្តកិច្ចសហការលើការងារនេះ ឱ្យមានប្រសិទ្ធភាព ។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៧
ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

អ៊ឹម សួស្ដី